**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
No. ១៧៦ MOC / SM 2010

# ប្រកាស

## ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃលទ្ធកម្មសម្រាប់គម្រោងកម្មវិធីគាំទ្រ ការអភិវឌ្ឍន៍ពាណិជ្ជកម្ម និងការពង្រឹងក្របខ័ណ្ឌសមាហរណកម្មពាណិជ្ជកម្ម

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ០២ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
-បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់ក្រសួងពាណិជ្ជកម្ម
-បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការដាក់អោយប្រើប្រាស់នូវនីតិវិធីរួមសម្រាប់ការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងលទ្ធកម្មលើការអនុវត្តគំរោងហិរញ្ញប្បទានសហប្រតិបតិការពីធនាគារ ពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី
-បានឃើញប្រកាសលេខ ៥៨៧ សហវ ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការដាក់អោយប្រើនូវនីតិវិធីលទ្ធកម្មរួមសម្រាប់គំរោងជំនួយរបស់ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី
-យោងកិច្ចព្រមព្រៀងជំនួយហិរញ្ញប្បទានរវាងធនាគារពិភពលោក និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ២០០៩ ស្តីពីជំនួយហិរញ្ញប្បទានសម្រាប់គំរោងកម្មវិធីគាំទ្រការអភិវឌ្ឍន៍ពាណិជ្ជកម្ម
-យោងអនុសារណៈយោគយល់គ្នា រវាងក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា និងអង្គការសហប្រជាជាតិស្តីពីសេវាកម្មគំរោង ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០១០
-យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## ស ម្រេ ច

**ប្រការ ១.-**

បង្កើតគណៈកម្មកាវាយតម្លៃលទ្ធកម្មគម្រោងកម្មវិធីគាំទ្រការអភិវឌ្ឍន៍ពាណិជ្ជកម្ម និងការពង្រឹងក្របខ័ណ្ឌសមាហរណកម្មពាណិជ្ជកម្មជា ៣ កំរិត គឺ "គណៈកម្មការវាយ តម្លៃលទ្ធកម្មកំរិតធំ" "គណៈកម្មកាវាយតម្លៃលទ្ធកម្មកំរិតទូទៅ" និង "គណៈកម្មកាវាយតម្លៃលទ្ធកម្មកំរិតតូច"។ គណៈកម្មការវាយតម្លៃ លទ្ធកម្មនីមួយៗមានតួនាទី



ក្រសួងពាណិជ្ជកម្ម
មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥)-២៣ ៨៦៦ ០៨៨/៨៦៦ ៩៧៨
ទូរសារលេខ: (៨៥៥)-២៣ ៨៦៦ ១៨៨/៨៦៦ ៩២៥
អ៊ីម៉ែល :moccab@moc.gov.kh

និងភារកិច្ចអនុវត្តការងារដូចមាន ចែងនៅក្នុងនីតិវិធីលទ្ធកម្មរួមសម្រាប់គម្រោងជំនួយ របស់ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី ។

**ប្រការ ២.-**

គណៈកម្មការវាយតម្លៃលទ្ធកម្មក៏រិតធំមានសមាសភាពដូចខាងក្រោម:

| | | |
|---|---|---|
| ១- ឯកឧត្តម | **ចម ប្រសិទ្ធ** | ប្រធាន |
| ២- ឯកឧត្តម | **ប៉ាន សូរស័ក្តិ** | អនុប្រធានទី១ |
| ៣- ឯកឧត្តម | **សុខ សុភ័ក្រ្ត** | អនុប្រធានទី២ |
| ៤- លោក | **អ៊ុច គីមយ៉ុន** | លេខាធិការ |
| ៥- លោក | **ហង់ សុជីវិន** | សមាជិក |
| ៦- លោក | **សួន ប្រសិទ្ធ** | សមាជិក |
| ៧- តំណាងអង្គភាពប្រតិបត្តិគម្រោង | | សមាជិក |
| ៨- តំណាងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | សមាជិក |
| ៩- តំណាងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | សមាជិក |

គណៈកម្មកាវាយតម្លៃលទ្ធកម្មក៏រិតទូទៅមានសមាសភាពដូខាងក្រោម:

| | | |
|---|---|---|
| ១- ឯកឧត្តម | **ប៉ាន សូរស័ក្តិ** | ប្រធាន |
| ២- ឯកឧត្តម | **សុខ សុភ័ក្រ្ត** | អនុប្រធានទី១ |
| ៣- លោក | **អ៊ុច គីមយ៉ុន** | អនុប្រធានទី២ |
| ៤- លោក | **ហង់ សុជីវិន** | លេខាធិការ |
| ៥- តំណាងអង្គភាពប្រតិបត្តិគម្រោង | | សមាជិក |
| ៦- តំណាងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | សមាជិក |
| ៧- តំណាងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | សមាជិក |

គណៈកម្មការវាយតម្លៃលទ្ធកម្មក៏រិតតូចមានសមាសភាពដូខាងក្រោម:

| | | |
|---|---|---|
| ១- ឯកឧត្តម | **ប៉ាន សូរស័ក្តិ** | ប្រធាន |
| ២- ឯកឧត្តម | **សុខ សុភ័ក្រ្ត** | អនុប្រធានទី១ |
| ៣- លោក | **អ៊ុច គីមយ៉ុន** | អនុប្រធានទី២ |
| ៤- លោក | **សួន ប្រសិទ្ធ** | លេខាធិការ |
| ៥- មន្ត្រីបច្ចេកទេសគម្រោង | | សមាជិក |
| ៦- មន្ត្រីហិរញ្ញវត្ថុគម្រោង ឬតំណាងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | សមាជិក |

**ប្រការ ៣.-**

គណៈកម្មកាវាយតម្លៃលទ្ធកម្មគម្រោងកម្មវិធីគាំទ្រការអភិវឌ្ឍន៍ពាណិជ្ជកម្ម និងគម្រោងការពង្រឹងក្របខ័ណ្ឌសមាហ- រណកម្មពាណិជ្ជកម្មត្រូវទទួលខុសត្រូវលើការត្រួតពិនិត្យវាយតម្លៃ និងអនុម័តលើកិច្ចការងារលទ្ធកម្មជាទំនិញ សំណង់ស៊ីវិល និងសេវាកម្ម មានទឹកប្រាក់ដូចបានកំណត់ដោយឧបសម្ព័ន្ធ **៥** នៃនីតិវិធីលទ្ធកម្មរួមសម្រាប់គម្រោងជំនួយ របស់ធនាគារពិភព លោក និងធនាគារអភិវឌ្ឍន៍អាស៊ី ដែលមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។



ក្រសួងពាណិជ្ជកម្ម
មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥)-២៣ ៨៦៦ ០៨៨/៨៦៦ ៨៧៨
ទូរសារលេខ: (៨៥៥)-២៣ ៨៦៦ ១៨៨/៨៦៦ ៨២៥
អ៊ីម៉ែល :moccab@moc.gov.kh

**ប្រការ ៤.~**

ប្រធាន អនុប្រធានរបស់គណៈកម្មការវាយតម្លៃលទ្ធកម្ម ឬសមាជិកមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចអញ្ជើញអ្នកសង្កេតការណ៍ចូលរួមនៅក្នុងកិច្ចប្រជុំលទ្ធកម្មនីមួយៗ របស់គណៈកម្មការវាយតម្លៃលទ្ធកម្ម ប៉ុន្តែអ្នកសង្កេតការណ៍មិនត្រូវ បានអនុញ្ញាតឱ្យចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចឡើយ។ លេខាធិការមានតួនាទី និងភារកិច្ចកត់ត្រារាល់ការងារការត្រួតពិនិត្យវាយតម្លៃ របស់គណៈកម្មការនីមួយៗរៀបចំរបាយការណ៍ និងឯកសារចាំបាច់នានាសម្រាប់ហត្ថលេខាដោយប្រធាន ។

ក្នុងករណីប្រធាននៃគណៈកម្មការនីមួយៗ អវត្តមាន អនុប្រធានទី១ មានសិទ្ធិជាស្វ័យប្រវត្តិក្នុងការដឹកនាំកិច្ចប្រជុំនេះ ដើម្បីជៀសវាងការរាំងស្ទះដល់ការងារធ្វើលទ្ធកម្មឱ្យគម្រោង។ ក្នុងករណីប្រធាន និងអនុប្រធានទី១ អវត្តមាន អនុប្រធានទី២ មានសិទ្ធិជាស្វ័យប្រវត្តិក្នុងការដឹកនាំកិច្ចប្រជុំនេះ ដើម្បីជៀសវាងការរាំងស្ទះដល់ការងារធ្វើលទ្ធកម្មរបស់គម្រោង ។ លទ្ធផលនៃ កិច្ចប្រជុំត្រូវរាយការណ៍ជូនប្រធាន និងអនុប្រធាន និងអនុប្រធាន ដើម្បីធ្វើការតាមដានបន្ត ។

**ប្រការ ៥.~**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៦.~**

នាយិកាខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋាន ពាណិជ្ជកម្មក្នុងប្រទេស អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គាធិការនៃអគ្គាធិការដ្ឋាន និងសាមីខ្លួនត្រូវអនុវត្ត តាមភារកិច្ចរៀងៗខ្លួន តាមខ្លឹមសារនៃប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១០

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**<u>ចម្លងជូន:</u>**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធនាគារពិភពលោក
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ



ក្រសួងពាណិជ្ជកម្ម
មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥)-២៣ ៨៦៦ ០៨៨/៨៦៦ ៨៧៨
ទូរសារលេខ: (៨៥៥)-២៣ ៨៦៦ ១៨៨/៨៦៦ ៨២៥
អ៊ីម៉ែល :moccab@moc.gov.kh

# ឧបសម្ព័ន្ធ ៥ នៃនីតិវិធីលទ្ធកម្មរួមសម្រាប់គម្រោងជំនួយរបស់ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី

## ដំណើរការលទ្ធកម្ម និងត្រួតពិនិត្យមើលពី ”តម្លៃ តាមកំរិតនៃទឹកប្រាក់

<table>
<tr><th colspan="5">លទ្ធកម្មមានកំរិតទឹកប្រាក់តូច</th></tr>
<tr><td colspan="5">សមាជិក</td></tr>
<tr><td colspan="2">ប្រធានគម្រោង</td><td colspan="2">មន្ត្រីបច្ចេកទេសគម្រោង</td><td>មន្ត្រីហិរញ្ញវត្ថុគម្រោង ( មន្ត្រីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)</td></tr>
<tr><td colspan="5">កំរិតប្រាក់បានកំណត់</td></tr>
<tr><td colspan="2">ទំនិញលើសពី ២៥ ០០០ ដុល្លាសហរដ្ឋអាមេរិក</td><td colspan="2">សំណង់ស៊ីវិលលើសពី ៥០ ០០០ ដុល្លាសហរដ្ឋអាមេរិក</td><td>សេវាលើសពី ៥ ០០០ ដុល្លាសហរដ្ឋអាមេរិក</td></tr>
<tr><th colspan="5">លទ្ធកម្មមានកំរិតទឹកប្រាក់មធ្យមឬទូទៅ</th></tr>
<tr><td colspan="5">សមាជិក</td></tr>
<tr><td>នាយកគម្រោង</td><td>ប្រធានគម្រោង</td><td>តំណាងអង្គភាពប្រតិបត្តិ</td><td>តំណាងមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ</td><td>មន្ត្រីហិរញ្ញវត្ថុគម្រោង ( មន្ត្រីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)</td></tr>
<tr><td colspan="5">កំរិតប្រាក់បានកំណត់</td></tr>
<tr><td colspan="2">ទំនិញលើស និងចាប់ពី ២៥ ០០០-៥០០ ០០០ ដុល្លាសហរដ្ឋអាមេរិក</td><td colspan="2">សំណង់ស៊ីវិលលើស និងចាប់ពី ៥០ ០០០-៣ ០០០ ០០០ ដុល្លាសហរដ្ឋអាមេរិកឡើងទៅ</td><td>សេវាលើស និងចាប់ពី ៥ ០០០-៥០០ ០០០ ដុល្លាសហរដ្ឋអាមេរិក</td></tr>
<tr><th colspan="5">លទ្ធកម្មមានកំរិតទឹកប្រាក់ធំ</th></tr>
<tr><td colspan="5">សមាជិក</td></tr>
<tr><td>ប្រធានភ្នាក់ងារប្រតិបត្តិគម្រោង</td><td>នាយកគម្រោង</td><td>តំណាងអង្គភាពប្រតិបត្តិ</td><td>តំណាងមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ</td><td>តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ</td></tr>
<tr><td colspan="5">កំរិតប្រាក់បានកំណត់</td></tr>
<tr><td colspan="2">ទំនិញលើសពី ៥០០ ០០០ ដុល្លាសហរដ្ឋអាមេរិក</td><td colspan="2">សំណង់ស៊ីវិលលើសពី ៣ ០០០ ០០០ ដុល្លាសហរដ្ឋអាមេរិក</td><td>សេវាលើសពី ៥០០ ០០០ ដុល្លាសហរដ្ឋអាមេរិក</td></tr>
</table>

## កម្រិតទឹកប្រាក់លទ្ធកម្មទំនិញ

| ដំណើរការ | កម្រិតទឹកប្រាក់ |
|---|---|
| ការដាក់ដេញថ្លៃប្រកួតប្រជែងជាអន្តរជាតិ | រាល់ការធ្វើលទ្ធកម្មលើសពីទឹកប្រាក់១០០ ០០០ ដុល្លាសហរដ្ឋអាមេរិក |
| ការដាក់ដេញថ្លៃប្រកួតប្រជែងជាអន្តរជាតិមានការកំណត់ | មានតែនៅពេលបានបញ្ជាក់ជាពិសេសក្រោមកិច្ចព្រមព្រៀងស្របច្បាប់របស់គម្រោង ឬមិនបានជំទាស់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬទីភ្នាក់ងារផ្តល់ជំនួយ ផ្អែកលើករណីលើកលែងណាមួយ |
| ការដាក់ដេញថ្លៃប្រកួតប្រជែងលក្ខណៈជាតិ | រាល់ការធ្វើលទ្ធកម្មលើសពីទឹកប្រាក់ ២០ ០០០ ដុល្លាសហរដ្ឋអាមេរិក និងក្រោមទឹកប្រាក់ ១០០ ០០០ ដុល្លាសហរដ្ឋអាមេរិក |
| ទិញទំនិញតាមហាងដោយមានការផ្សាយពាណិជ្ជកម្ម | រាល់ការធ្វើលទ្ធកម្មលើសពីទឹកប្រាក់ ៥ ០០០ ដុល្លាសហរដ្ឋអាមេរិក និងក្រោមទឹកប្រាក់ ២០ ០០០ ដុល្លាសហរដ្ឋអាមេរិក |
| ទិញទំនិញតាមហាងដោយគ្មានការផ្សាយពាណិជ្ជកម្ម | រាល់ការធ្វើលទ្ធកម្មក្រោមទឹកប្រាក់ ៥ ០០០ ដុល្លាសហរដ្ឋអាមេរិក |
| ប្រាក់បន្តិចបន្តួចទុកសម្រាប់ចាយវាយ ឬការបញ្ជាទិញ | រាល់ការធ្វើលទ្ធកម្មក្រោមទឹកប្រាក់ ៥០០ ដុល្លាសហរដ្ឋអាមេរិក |
| ការចុះកិច្ចសន្យាផ្ទាល់ | មានតែនៅពេលបានបញ្ជាក់ជាពិសេសក្រោមកិច្ចព្រមព្រៀងស្របច្បាប់របស់គម្រោង ឬមិនបានជំទាស់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងទីភ្នាក់ងារផ្តល់ជំនួយ ផ្អែកលើករណីលើកលែងណាមួយ |

## កម្រិតទឹកប្រាក់លទ្ធកម្មសំណង់ស៊ីវិល

| ដំណើរការ | កម្រិតទឹកប្រាក់ |
|---|---|
| ការដាក់ដេញថ្លៃប្រកួតប្រជែងជាអន្តរជាតិ | រាល់ការធ្វើលទ្ធកម្មលើសពីទឹកប្រាក់ ៣០០ ០០០ ដុល្លាសហរដ្ឋអាមេរិក |
| ការដាក់ដេញថ្លៃប្រកួតប្រជែងលក្ខណៈជាតិ | រាល់ការធ្វើលទ្ធកម្មលើសពីទឹកប្រាក់ ៤០ ០០០ ដុល្លាសហរដ្ឋអាមេរិក និងក្រោមទឹកប្រាក់ ៣០០ ០០០ ដុល្លាសហរដ្ឋអាមេរិក |
| ទិញទំនិញតាមហាងដោយមានការផ្សាយពាណិជ្ជកម្ម | រាល់ការធ្វើលទ្ធកម្មលើសពីទឹកប្រាក់ ៥ ០០០ ដុល្លាសហរដ្ឋអាមេរិក និងក្រោមទឹកប្រាក់ ៤០ ០០០ ដុល្លាសហរដ្ឋអាមេរិក |
| ទិញទំនិញតាមហាងដោយគ្មានការផ្សាយពាណិជ្ជកម្ម | រាល់ការធ្វើលទ្ធកម្មក្រោមទឹកប្រាក់ ៥ ០០០ ដុល្លាសហរដ្ឋអាមេរិក |
| ការចុះកិច្ចសន្យាផ្ទាល់ | មានតែនៅពេលបានបញ្ជាក់ជាពិសេសក្រោមកិច្ចព្រមព្រៀងស្របច្បាប់របស់គម្រោងឬមិនបានជំទាស់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងទីភ្នាក់ងារផ្តល់ជំនួយ ផ្អែកលើករណីលើកលែងណាមួយ |
| ប្រើប្រាស់ធនធានដែលមានស្រាប់ | មានតែនៅពេលបានបញ្ជាក់ជាពិសេសក្រោមកិច្ចព្រមព្រៀងស្របច្បាប់របស់គម្រោង ឬមិនបានជំទាស់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងទីភ្នាក់ងារផ្តល់ជំនួយ ផ្អែកលើករណីលើកលែងណាមួយ |

# កំរិតទឹកប្រាក់លទ្ធកម្មសេវាកម្ម

| ដំណើរការ | កំរិតទឹកប្រាក់ |
|---|---|
| រាល់ការធ្វើលទ្ធកម្មសេវាកម្មដែលមានទឹកប្រាក់លើសពី ១០០ ០០០ ដុល្លាសហរដ្ឋអាមេរិកឡើងទៅត្រូវតែធ្វើការផ្សាយពាណិជ្ជកម្មជា អន្តរជាតិ ។<br>រាល់ការផ្តល់ជូននូវកិច្ចសន្យាទាំងឡាយត្រូវតែធ្វើការប្រកាសផ្សព្វផ្សាយដោយផ្អែកតាមនីតិវិធីរបស់អ្នកផ្តល់ជំនួយ ។ | |
| ការជ្រើសរើសផ្អែកលើគុណភាព | មានតែនៅពេលបានបញ្ជាក់ជាពិសេសក្រោមកិច្ចព្រមព្រៀងស្របច្បាប់របស់គម្រោងឬមិនបានជំទាស់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬទីភ្នាក់ងារផ្តល់ជំនួយ ផ្អែកលើករណីលើកលែងណាមួយ |
| ការជ្រើសរើសផ្អែកលើថ្លៃគុណភាព ជាលក្ខណៈអន្តរជាតិ | រាល់ការធ្វើលទ្ធកម្មមានទឹកប្រាក់លើសពី ១០០ ០០០ ដុល្លាសហរដ្ឋអាមេរិក |
| ការជ្រើសរើសផ្អែកលើថ្លៃគុណភាព ជាលក្ខណៈជាតិ | រាល់ការធ្វើលទ្ធកម្មមានទឹកប្រាក់ក្រោម ១០០ ០០០ និងលើស ៥០ ០០០ ដុល្លាសហរដ្ឋអាមេរិក ហើយនៅពេលដែលបញ្ជីជ្រើសរើសត្រូវបានកំណត់មានទីប្រឹក្សាថ្នាក់ ជាតិមានគុណសម្បត្តិគ្រប់គ្រាន់ ដើម្បីបំពេញការតាមការកំណត់ឱ្យ |
| ការជ្រើសរើសក្រោមថវិកាបានកំណត់ | មិនត្រូវបានប្រើលើគម្រោងជំនួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី គ្មានកំណត់កំរិតទឹកប្រាក់ ។ មានតែនៅពេលបានបញ្ជាក់ជាពិសេសក្រោមកិច្ចព្រមព្រៀងស្របច្បាប់ របស់គម្រោង ឬមិនបានជំទាស់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងទីភ្នាក់ងារផ្តល់ជំនួយផ្អែកលើករណីលើកលែងណាមួយ |
| ការជ្រើសរើសផ្អែកលើថ្លៃតិចបំផុត | មិនត្រូវបានប្រើលើគម្រោងជំនួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីនោះទេ ។<br>មានតែនៅពេលបានបញ្ជាក់ជាពិសេសក្រោមកិច្ចព្រមព្រៀងស្របច្បាប់របស់គម្រោង ឬមិនបានជំទាស់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងទីភ្នាក់ងារផ្តល់ជំនួយផ្អែកលើករណីលើកលែងណាមួយ |
| ការជ្រើសរើសផ្អែកតាមគុណវុឌ្ឍន៍របស់ទីប្រឹក្សា | រាល់ការធ្វើលទ្ធកម្មមានទឹកប្រាក់ក្រោម ៥០ ០០០ ដុល្លាសហរដ្ឋអាមេរិក |
| ការជ្រើសរើសតាមប្រភពតែមួយគត់ | មានតែនៅពេលបានបញ្ជាក់ជាពិសេសក្រោមកិច្ចព្រមព្រៀងស្របច្បាប់របស់គម្រោង ឬមិនបានជំទាស់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងទីភ្នាក់ងារផ្តល់ជំនួយ ផ្អែកលើករណីលើកលែងណាមួយ |
| ការជ្រើសរើសទីប្រឹក្សាឯកត្តជន | មានតែនៅពេលបានបញ្ជាក់ជាពិសេសក្រោមកិច្ចព្រមព្រៀងស្របច្បាប់របស់គម្រោង ឬមិនបានជំទាស់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងទីភ្នាក់ងារផ្តល់ជំនួយ ផ្អែកលើករណីលើកលែងណាមួយ |

*សម្គាល់: បកប្រែពីឯកសារនីតិវិធីលទ្ធកម្មរួមជាភាសាអង់គ្លេសមកជាភាសាខ្មែរសម្រាប់ជាឧបសម្ព័ន្ធនៃប្រកាស*